ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
**Nation - Religion - King**

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១២២៦ ព.ណ. ករ

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៧

# សេចក្តីជូនដំណឹង

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទូទៅឱ្យបានជ្រាបថា៖ ក្នុងយុទ្ធសាស្ត្រជួយជំរុញ និងលើកកម្ពស់ផលិតផលក្នុងស្រុកឱ្យមានការទទួលស្គាល់ និងចូលរួមប្រើប្រាស់កាន់តែទូលំទូលាយនៅទូទាំងប្រទេស ក្រសួងពាណិជ្ជកម្ម នឹងរៀបចំពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ ក្នុងឱកាស "យុទ្ធនាការទិញផលិតផលខ្មែរ" ឆ្នាំ២០១៧ នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង ចាប់ពីថ្ងៃទី២៥-២៨ ខែឧសភា ឆ្នាំ២០១៧។

ពិព័រណ៍ពាណិជ្ជកម្មនេះ នឹងត្រូវរៀបចំឡើងក្នុងគោលបំណងដើម្បីពញ្ញាក់ស្មារតីមហាជនទូទៅ ឱ្យងាកមកគាំទ្រ និងប្រើប្រាស់ផលិតផលក្នុងស្រុកឱ្យបានច្រើនជាអតិបរិមា។ ក្រសួងពាណិជ្ជកម្ម នឹងប្រមូលកៀរគរផលិតផលខ្មែរ ដែលមានគុណភាពខ្ពស់ មានសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ មានការវេចខ្ចប់បានល្អត្រឹមត្រូវ អនុលោមតាមស្តង់ដារផលិតកម្ម ពីគ្រប់ទិសទីនៅទូទាំងប្រទេស មកដាក់តាំងបង្ហាញ និងបង្កឱកាសត្រូវលោក លោកស្រី ស្វែងរកដៃគូយកទៅលក់បន្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី ដែលមានបំណងចូលរួមតាំងបង្ហាញផលិតផលខ្មែរក្នុងព្រឹត្តិការណ៍នេះ មេត្តាប្រញាប់រួសរាន់មកដាក់ពាក្យចូលរួម ព្រោះចំនួនស្តង់មានកំណត់។ ជាមួយគ្នានេះ ក្រសួងពាណិជ្ជកម្ម សូមអញ្ជើញសាធារណជនទូទៅចូលរួមទស្សនា និងគាំទ្រព្រឹត្តិការណ៍ដ៏មានសារៈសំខាន់នេះ កុំបីខកខានឡើយ។

ចំពោះព័ត៌មានលម្អិតផ្សេងៗ ស្តីពីការរៀបចំពិព័រណ៍ខាងលើ សូមទំនាក់ទំនងនាយកដ្ឋានកិច្ចការពិព័រណ៍នៃអគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម ក្រសួងពាណិជ្ជកម្ម តាមទូរស័ព្ទលេខ ០៧៧ ៣៣៩ ៤៣៩/០១៥ ៥៥៣ ៣៥៥/០៧៧ ៣៣២ ២៣៣/០៩៨ ៨៤២ ១១៩ ឬអ៊ីម៉ែល៖ neary86@yahoo.com / rithyco@yahoo.com / vuthakep@yahoo.com / sok.darith@moc.gov.kh។

**សូមអរគុណ!**

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

នាយកដ្ឋានកិច្ចការពិព័រណ៍

# ពាក្យសុំចុះឈ្មោះ

## ចូលរួមពិព័រណ៍ពាណិជ្ជកម្មផលិតផលខ្មែរ

## នាឱកាសយុទ្ធនាការទិញផលិតផលខ្មែរ

នៅខេត្តបាត់ដំបង ចាប់ពីថ្ងៃទី២៥-២៨ ខែឧសភា ឆ្នាំ២០១៧

### ១.ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ឈ្មោះក្រុមហ៊ុន | |
| ឈ្មោះប្រធានក្រុមហ៊ុន | |
| អាសយដ្ឋានក្រុមហ៊ុន | |
| ទូរស័ព្ទ ឬទូរសារ | |
| អ៊ីមែល | |

### ២.ព័ត៌មានអំពីប្រភេទផលិតផល

| ប្រភេទផលិតផល | | រាយមុខផលិតផល |
|---|---|---|
| កសិផល | ☐ | |
| ជលផល | ☐ | |
| ផលិតផលម្ហូបអាហារ | ☐ | |
| ផលិតផលភេសជ្ជៈ | ☐ | |
| ផលិតផលសិប្បកម្ម | ☐ | |
| ផលិតផលឧស្សាហកម្ម | ☐ | |
| គ្រឿងសង្ហារិម | ☐ | |
| សេវាកម្ម | ☐ | |

### ៣-លក្ខខណ្ឌនៃការចូលរួម

-ត្រូវរៀបចំស្តង់របស់ខ្លួនឱ្យបានរួចរាល់មុន០១ថ្ងៃ នៃថ្ងៃបើកសម្ពោធពិព័រណ៍

-មិនអនុញ្ញាត ឱ្យលក់ផលិតផលផ្សេងៗដែលមិនមានបំពេញនៅក្នុងបែបបទខាងលើ

-មិនអនុញ្ញាត ផ្ទេរស្តង់ ឬក៏ទុកស្តង់នូវទំនេរក្នុងរយៈពេលនៃការតាំងពិព័រណ៍

ក្នុងករណីមិនបានអនុវត្តន៍ ដូចបានជម្រាបជូនខាងលើ គណៈកម្មការមានសិទ្ធិបិទស្តង់ ឬដកហូតស្តង់មកវិញ ហើយរាល់ការចំណាយសាងសង់ស្តង់ជាបន្ទុករបស់ម្ចាស់ស្តង់។

ខ្ញុំបាទ/នាងខ្ញុំ ជាប្រធាន/តំណាងក្រុមហ៊ុន សូមធានាអះអាងថា ការឆ្លើយនូវសំណួរខាងលើពិតជាត្រឹមត្រូវពិតប្រាកដមែន។ បើខុសពីការពិត ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវចំពោះមុខច្បាប់។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

**ប្រធាន/តំណាងក្រុមហ៊ុន**